**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសារព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងរួមចំណែកក្នុងការផ្តល់នូវអាហារូបត្ថម្ភឱ្យបានសព្វគ្រប់ និងមានសុវត្ថិភាពដល់ ទារក និងកុមារតូចៗ តាមរយៈ ការគាំពារ និងការលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ និងការជំរុញលើកទឹកចិត្តឱ្យមានការផ្តល់អាហារបន្ថែមឱ្យបានត្រឹមត្រូវ និងស្របតាមអាយុកំណត់របស់ទារក និងកុមារ ដើម្បីធានាឱ្យមានការប្រើប្រាស់សមស្របនូវផលិតផលជំនួសទឹកដោះម្តាយតែនៅពេលណាដែលចាំបាច់ និងដោយមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ កំណត់អំពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ក្នុងនោះមានផលិតផល ដែលផលិតក្នុងប្រទេស និងផលិតផលនាំចូលពីបរទេស សម្រាប់បម្រើតម្រូវការប្រើប្រាស់ក្នុងការចិញ្ចឹមទារក រហូតដល់អាយុគ្រប់ ១២ ខែ និងកុមារតូចៗរហូតដល់អាយុ ២៤ ខែ ។

អនុក្រឹត្យនេះ មានអានុភាព និងត្រូវអនុវត្តចំពោះ គុណភាព និងវត្តមាន នៃព័ត៌មានទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ផលិតផលដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ប្រភេទផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ រួមមាន ÷

- ក- ទឹកដោះគោម្សៅផ្សំតាមរូបមន្ត រួមបញ្ចូលទាំង ទឹកដោះគោម្សៅផ្សំតាមរូបមន្តពិសេស ។
- ខ- រាល់ផលិតផលទាំងអស់ដែលត្រូវបានផ្សព្វផ្សាយលក់ ឬបញ្ជាក់បង្ហាញថា សមស្របសម្រាប់ចិញ្ចឹមទារក និងកុមារតូចៗ ។
- គ- ដបបំបៅ ក្បាលដោះដៃ និងគ្រឿងសម្រាប់ទារកជញ្ជក់លេង ។
- ឃ- ទឹកដោះគោផ្សំតាមរូបមន្ត សម្រាប់កុមារចាប់ពីអាយុ ៦ ខែ ។
- ង- ផលិតផលផ្សេងទៀតដែលត្រូវបានកំណត់ដោយប្រកាសរួមរវាងក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធ ។

# ជំពូកទី ២

# និយមន័យ

**មាត្រា ៤.-**

បច្ចេកស័ព្ទខាងក្រោម សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តអនុក្រឹត្យនេះ ÷

១- **ការឃោសនាពាណិជ្ជកម្ម** សំដៅដល់ គ្រប់ទង្វើទាំងអស់របស់ផលិតករ អ្នកនាំចូល ឬអ្នកចែកចាយ ទោះជាតាមមធ្យោបាយណាក៏ដោយដែលមាន គោលបំណងផ្សព្វផ្សាយលក់ ចែកចាយ ប្រើប្រាស់ ឬដាក់តាំងលក់ផលិតផលដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។ ខាងក្រោមនេះ គឺជាផ្នែកមួយនៃការឃោសនា ពាណិជ្ជកម្ម ÷

- ក- ការបោះពុម្ពផ្សាយ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ ភាពយន្ត ប្រព័ន្ធអេឡិចត្រូនិច កាសែតវីដេអូ ឬ តាមទូរស័ព្ទ ។
- ខ- ការដាក់តាំងបង្ហាញផ្លាកសញ្ញាពាណិជ្ជកម្ម ផ្ទាំងព័ត៌មាន ផ្ទាំងរូបភាព ឬការបិទផ្សាយនានា ។
- គ- ការដាក់តាំងពិពណ៌រូបភាព ឬគំរូផលិតផលផ្សេងៗ ។

២- **សម្ភារៈផ្គត់ផ្គង់** សំដៅដល់ ផលិតផលក្នុងបរិមាណមួយ ដែលត្រូវផ្តល់អោយសម្រាប់ប្រើប្រាស់ ក្នុងរយៈពេលមួយកំណត់ ដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាប (ទាបជាងតម្លៃលក់រាយចំនួន ៨០ ភាគរយ) សម្រាប់គោលដៅសង្គមកិច្ច ដោយរាប់បញ្ចូលទាំង សម្ភារៈដែលត្រូវផ្តល់អោយក្រុមគ្រួសារដែលជួបប្រទះការខ្វះខាត ។

៣- **ការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់** សំដៅដល់ គ្រប់វិធីសាស្ត្រទាំងអស់ ដែលត្រូវប្រើប្រាស់ ទោះផ្ទាល់ក្តី ប្រយោលក្តី ដើម្បីជំរុញលើកទឹកចិត្តអោយបុគ្គលប្រើប្រាស់ផលិតផល ដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។

៤- **ការផ្សព្វផ្សាយលក់** សំដៅដល់ ការផ្សព្វផ្សាយលក់ផលិតផល ការចែកចាយ ការឃោសនាពាណិជ្ជកម្ម ទំនាក់ទំនងសាធារណៈអំពីផលិតផល និងសេវាផ្សព្វផ្សាយព័ត៌មាន ។

៥- **កុមារតូចៗ** សំដៅដល់ កុមារចាប់ពីអាយុពី១២ ខែ រហូតដល់ ២៤ ខែ ។

៦- **គំរូសាក** សំដៅដល់ ផលិតផលក្នុងបរិមាណមួយតិចតួច ដែលត្រូវបានផ្តល់អោយដោយឥតគិតថ្លៃ ។

៧- **គ្រឿងសម្រាប់ទារកជញ្ជក់លេង** សំដៅដល់ ក្បាលដោះសិប្បនិម្មិត សម្រាប់ទារកជញ្ជក់ ដែលអាចហៅថា ក្បាលដោះជ័រផងដែរ ។

៨- **បុគ្គលិកសុខាភិបាល** សំដៅដល់ បុគ្គលដែលផ្តល់សេវាថែទាំសុខភាព ឬ បុគ្គលកំពុងទទួលការបណ្តុះបណ្តាលអំពីផ្នែកថែទាំសុខភាព នៅក្នុងប្រព័ន្ធថែទាំសុខភាព ទោះបីជាមានមុខវិជ្ជាជីវៈ ឬមិនមានមុខវិជ្ជាជីវៈ ក៏ដោយ រាប់បញ្ចូលទាំង ឆ្មបបុរាណ បុគ្គលិកស្ម័គ្រចិត្ត និងបុគ្គលិកមិនមានប្រាក់បៀវត្សរ៍ ។

៩- **បុគ្គលិកផ្នែកផ្សព្វផ្សាយលក់** សំដៅដល់ បុគ្គលដែលមានមុខងារពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផល ដែលមាននៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ។

១០- **ប្រព័ន្ធថែទាំសុខភាព** សំដៅដល់ ស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នឯកជន

ដែលចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងការថែទាំសុខភាព ឬការអប់រំសុខភាព ដល់ស្ត្រីជាមាតាទារក និងស្ត្រីមានផ្ទៃពោះ ដោយរាប់បញ្ចូលទាំងទារកដ្ឋាន និងមជ្ឈមណ្ឌលថែទាំទារក និងកុមារ ។ បុគ្គលិកថែទាំសុខភាពនៅក្នុងវិស័យឯកជន ក៏ស្ថិតនៅក្នុងប្រព័ន្ធនេះដែរ ។

១១-**ស្លាកសញ្ញា** សំដៅដល់ រាល់ផ្លាកសញ្ញាពាណិជ្ជកម្ម ម៉ាក រូបភាព ឬសេចក្តីពិពណ៌នាផ្សេងៗ ដែលសរសេរជា លាយលក្ខណ៍អក្សរ បោះពុម្ព ផ្តិតស្តង់ស៊ីល គូស រំលេចជាក្បាច់ ឬស្លាម ឬបិទភ្ជាប់ទៅនឹងសម្បកផលិតផលទាំងអស់ ដែលមាននៅក្នុងខ្លឹមសារ និងវិសាលភាពនៃអនុក្រឹត្យនេះ ។

១២-**ការធ្វើស្លាក** សំដៅដល់ ការគិតបញ្ចូលនូវទាំងអ្វីៗដែលបានសរសេរ បោះពុម្ព ឬជាក្រាហ្វិកដែលបានបង្ហាញនៅលើស្លាកផលិតផលទៅតាមចរិកពិតរបស់ចំណីអាហារ ឬបានដាក់បង្ហាញនៅជិតចំណីអាហារគិតទាំងអ្វីដែលសម្រាប់បម្រើការផ្សព្វផ្សាយលក់ផងដែរ ។

១៣-**ផលិតផលជំនួសទឹកដោះម្តាយ** សំដៅដល់ រាល់អាហារទាំងឡាយណាដែលត្រូវបានផ្សព្វផ្សាយលក់ ឬធ្វើការបង្ហាញ ដែលអាចជំនួសទឹកដោះម្តាយមួយផ្នែកឬទាំងស្រុង ទោះសមស្រប ឬមិនសមស្របតាមគោលបំណងនេះក៏ដោយ ។

១៤-**ផលិតករ** សំដៅដល់ សាជីវកម្ម ឬអង្គភាពដទៃទៀតនៅក្នុងវិស័យសាធារណៈ ឬឯកជន ដែលមានការងារ ឬមុខងារធ្វើផលិតផលដែលស្ថិតនៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ទោះជាដោយផ្ទាល់ក្តី ឬតាមរយៈភ្នាក់ងារណាមួយក្តី ឬតាមរយៈអង្គភាពក្រោមឱវាទក្តី ឬជាប់កិច្ចសន្យាជាមួយនឹងខ្លួនក្តី ។

១៥-**ទារក** សំដៅដល់ កុមារចាប់តាំងពីកើតរហូតដល់អាយុ ១២ ខែ ។

១៦-**ទឹកដោះគោម្សៅផ្សំតាមរូបមន្ត** សំដៅដល់ ផលិតផលជំនួសទឹកដោះម្តាយ ដែលផលិតដោយរោងចក្រតាមស្តង់ដារចំណីអាហារ (Codex Alimentarius) ដើម្បីបំពេញសេចក្តីត្រូវការធម្មតារបស់ទារកចាប់ពីពេលកើតរហូតដល់អាយុ ៦ខែ ហើយ សមស្របទៅតាមលក្ខណៈសរីរៈសាស្ត្ររបស់កុមារ ។

១៧-**ទឹកដោះគោម្សៅផ្សំតាមរូបមន្តសម្រាប់បំប៉ន** សំដៅដល់ ទឹកដោះគោ ឬផលិតផលទឹកដោះគោ ដែលមានប្រភពមកពីសត្វ ឬបន្លែ ឬគ្រាប់ធញ្ញជាតិដែលត្រូវបានផលិតនៅក្នុងរោងចក្រ តាមស្តង់ដារចំណីអាហារ (Codex Alimentarius) ជាទឹកដោះគោម្សៅបំប៉ន ហើយត្រូវបានផ្សព្វផ្សាយលក់ ឬបង្ហាញថាសមស្របសម្រាប់ចិញ្ចឹមទារក និងកុមារដែលមានអាយុលើសពី ៦ ខែ ។

១៨-**ទឹកដោះគោម្សៅផ្សំតាមរូបមន្តពិសេស** សំដៅដល់ ទឹកដោះគោម្សៅផ្សំតាមរូបមន្ត សម្រាប់ទារកកើតមិនគ្រប់ខែ ឬទារកកើតមិនគ្រប់គីឡូ ឬសម្រាប់ទារកដែលមានប្រតិកម្មជាមួយនឹងទឹកដោះគោផ្ទាល់ ឬការបូអ៊ីដ្រាត ឬមានប្រព័ន្ធរាងកាយមិនប្រក្រតី ។

១៩-**សម្បកផលិតផល ឬកំប៉ុង** សំដៅដល់ រាល់ទម្រង់វេចខ្ចប់ផលិតផលដែលមាននៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ សម្រាប់លក់ដូរ ដូចជា លក់រាយធម្មតា ដោយរាប់បញ្ចូលទាំងសម្បកកេសខាងក្រៅផងដែរ ។

២០- **អាហារបន្ថែម** សំដៅដល់អាហារទាំងឡាយណា ទោះជាផលិតនៅក្នុងរោងចក្រ ឬធ្វើនៅតាមផ្ទះក្តី ដែលអាចបំពេញបន្ថែមទៅលើទឹកដោះម្តាយ នៅពេលដែលទឹកដោះម្តាយតែមួយមុខមិនគ្រប់គ្រាន់ សម្រាប់បំពេញសេចក្តីត្រូវការរបស់ទារក នៅពេលអាយុបាន ៦ ខែ ។

២១- **អ្នកចែកចាយ** សំដៅដល់បុគ្គល សាជីវកម្ម ឬអង្គភាពដទៃទៀត នៅក្នុងវិស័យសាធារណៈ ឬឯកជន ដែលមានមុខងារផ្សព្វផ្សាយលក់ដុំ ឬលក់រាយនូវផលិតផលដែលមាននៅក្នុងវិសាលភាពនៃអនុក្រឹត្យនេះ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។

២២- **អ្នកចែកចាយបឋម** សំដៅដល់ ភ្នាក់ងារលក់របស់អ្នកផលិត អ្នកតំណាង អ្នកចែកចាយក្នុងប្រទេស ឬអ្នកជើងសារ ។

២៣- **មន្ត្រីត្រួតពិនិត្យ** សំដៅដល់បុគ្គលដែលត្រូវបានតែងតាំង នៅក្រោមសមត្ថកិច្ចរបស់នាយកដ្ឋានឱសថ ចំណីអាហារ គ្រឿងសម្អាង និងបរិក្ខារពេទ្យ ជាមន្ត្រីត្រួតពិនិត្យ ដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាលបានផ្តល់សិទ្ធិអំណាចអោយ ដើម្បីអនុវត្តមុខងារនេះ តាមការចាំបាច់ ស្របតាមបញ្ញត្តិនៃអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

## ជំពូកទី ៣
## ការដាក់កម្រិតលើការផ្សព្វផ្សាយ
## ព័ត៌មាន និងការអប់រំ

### មាត្រា ៥.-

ក្រសួងសុខាភិបាលមានភារកិច្ចដាក់ចេញនូវគោលនយោបាយ និងផ្តល់ជូននូវព័ត៌មានសមស្របស្តីពីការចិញ្ចឹមទារក និងកុមារតូចៗដល់ក្រុមគ្រួសារ និងមន្ត្រីទាំងឡាយដែលធ្វើការពាក់ព័ន្ធនឹងផ្នែកអាហារូបត្ថម្ភទារក និងកុមារតូចៗ ដើម្បីឱ្យមានការយល់ដឹងអំពីវិធីផ្តល់ចំណីអាហារដល់ទារក និងកុមារតូចៗតាមរយៈការផ្សព្វផ្សាយព័ត៌មាន និងការអប់រំ។ ក្នុងការអនុវត្តភារកិច្ចខាងលើនេះ ក្រសួងសុខាភិបាលត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធនានាដែលបម្រើវិស័យនេះ ក្នុងករណីចាំបាច់ ។

### មាត្រា ៦.-

រាល់ព័ត៌មាន សម្ភារៈ ឬឯកសារអប់រំ ឬសម្ភារៈផ្សេងទៀត ទោះជាសរសេរជាលាយល័ក្ខណ៍អក្សរក្តី ថតជា សម្លេងក្តី ឬជារូបភាពក្តី ដែលទាក់ទងនឹងការចិញ្ចឹមទារក ដែលត្រូវបានផលិត និងរៀបចំឡើងដើម្បីប្រើនៅក្នុងប្រទេសដោយបុគ្គលណាក៏ដោយ ÷

១- ត្រូវពន្យល់ច្បាស់លាស់ពី ÷

ក- ផលប្រយោជន៍ និងឧត្តមភាពនៃការបំបៅកូនដោយទឹកដោះម្តាយ ។

ខ- របៀបផ្តួចផ្តើម និងបន្តការបំបៅកូនដោយទឹកដោះម្តាយ រួមបញ្ចូលទាំងអាហារូបត្ថម្ភសម្រាប់ម្តាយផង ។

គ- អនុសាសន៍ឱ្យបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ រយៈពេល ៦ ខែ ចាប់ពីពេលកើត និងបន្តការបំបៅកូនដោយទឹកដោះម្តាយ ក្រោយរយៈពេល ៦ ខែ រហូតដល់កុមារមានអាយុបាន ២ ឆ្នាំ ឬលើស ។

ឃ- របៀបរបប និងមូលហេតុនៃការចាប់ផ្តើមបំបៅដោយដប ឬការឆាប់ចាប់ផ្តើមផ្តល់អាហារបន្ថែម។ ការបំបៅដោយដបឬការឆាប់ចាប់ផ្តើមផ្តល់អាហារបន្ថែមនេះ ពិតជាមានការរំខានដល់ការបំបៅកូនដោយទឹកដោះម្តាយ ទោះបីជាការបំបៅដោយដបនោះមានការកំណត់ត្រឹមតែ ២ ឬ ៣ ដង ក្នុងមួយថ្ងៃ ក៏ដោយ ។

២- ត្រូវមានព័ត៌មានត្រឹមត្រូវ និងថ្មីៗ និងមិនត្រូវប្រើរូបភាព ឬអត្ថបទណាមួយដែលជំរុញលើកទឹកចិត្តឱ្យមានការបំបៅដោយដប ឬរារាំងដល់ការបំបៅកូនដោយទឹកដោះម្តាយឡើយ ។

៣- ត្រូវសរសេរជាអក្សរខ្មែរ ។

៤- មិនត្រូវយោងទៅផលិតផលទាំងឡាយណាដែលមានចែងក្នុងអនុក្រឹត្យនិងបទប្បញ្ញត្តិជាធរមាន ឬមានប្រើឈ្មោះ និមិត្តសញ្ញា ផ្លាកសញ្ញាពាណិជ្ជកម្ម ឬសេចក្តីពិពណ៌នារបស់ផលិតករ ឬអ្នកចែកចាយផលិតផលជាដាច់ខាត លើកលែងតែការបង្ហាញតាមបែបការរក្សាសិទ្ធិប៉ុណ្ណោះ ។

**មាត្រា ៧.-**

ប្រសិនបើសម្ភារៈ ឬឯកសារ ឬព័ត៌មាន ដាក់បញ្ចូលប្រធានបទស្តីពីការចិញ្ចឹមទារកដោយផលិតផលជំនួសទឹកដោះម្តាយ តាមរយៈការបំបៅដោយដប សម្ភារៈឬឯកសារ ឬព័ត៌មាននោះ ត្រូវបញ្ជាក់អោយបានច្បាស់ជាអាទិ៍អំពី :

- ការរៀបចំ និងការប្រើប្រាស់ត្រឹមត្រូវនូវផលិតផលនោះ
- ការប៉ាន់ស្មានថវិកាចំណាយទៅលើផលិតផលសម្រាប់ចិញ្ចឹមទារករយៈពេល ៦ ខែ
- គ្រោះថ្នាក់ចំពោះសុខភាពដែលបណ្តាលមកពីការបំបៅដោយដប និងការរៀបចំពុំបានត្រឹមត្រូវនូវផលិតផល
- របៀបបញ្ចុកទារកដោយប្រើពែង

**មាត្រា ៨.-**

ប្រសិនបើសម្ភារៈ ឬឯកសារទាំងនោះ ដាក់បញ្ចូលប្រធានបទស្តីពីការចិញ្ចឹមទារក ដោយផ្តល់អាហារបន្ថែម សម្ភារៈ ឬឯកសារទាំងនោះ ត្រូវមានការពន្យល់ណែនាំអំពី ÷

- គ្រោះថ្នាក់ចំពោះសុខភាពដែលបណ្តាលមកពីការចាប់ផ្តើមឱ្យអាហារបន្ថែមមុនទារកអាយុបាន ៦ ខែ
- អាហារបន្ថែមទាំងនោះ អាចរៀបចំធ្វើបានដោយស្រួលនៅតាមផ្ទះ ដោយប្រើគ្រឿងផ្សំដែលមាននៅក្នុងមូលដ្ឋាន នៅតាមទីកន្លែងរស់នៅដែលងាយរកបាន
- ផលប្រយោជន៍ និងតម្លៃនៃការបន្តការបំបៅកូនដោយទឹកដោះម្តាយ ក្រោយពេលដែលកុមារអាយុបាន ៦ ខែ រហូតដល់កុមារមានអាយុ ២ ឆ្នាំ ឬលើស ។

## ជំពូកទី ៤

## ស្លាកសញ្ញា

**មាត្រា ៩.-**

ស្លាកសញ្ញានៃផលិតផលសម្រាប់ទារក និងកុមារ ក្រៅពីល័ក្ខខ័ណ្ឌតម្រូវដូចមានចែងក្នុងស្តង់ដារឧស្សាហកម្មកម្ពុជាត្រូវបង្ហាញបន្ថែមនូវខ្លឹមសារដូចខាងក្រោម ÷

ក- សម្បកផលិតផល ឬស្លាកដែលភ្ជាប់នោះមាន តួអក្សរដែលងាយស្រួលអានបាន ។

ខ- ពាក្យនិយាយថាគ្មានអ្វីប្រសើរជាងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតបាន ៦ ខែ និងបន្តការបំបៅដោះម្តាយរហូតបានអាយុ ២ ឆ្នាំ ឬ លើសឡើយ ។

គ- ការណែនាំអំពីវិធីប្រើប្រាស់ និងការប្រើប្រាស់ និងការរៀបចំឱ្យបានត្រឹមត្រូវ ។

ឃ- បម្រាមដោយមានពាក្យកំណត់សម្គាល់អំពីគ្រោះថ្នាក់ដល់សុខភាព ដែលបណ្តាលមកពីការប្រើប្រាស់មិនបានត្រឹមត្រូវនូវផលិតផលដែលបានកំណត់ ។

ង- បម្រាមដែលចង្អុលបញ្ជាក់ពីគ្រោះថ្នាក់ដល់សុខភាពនៃការចាប់ផ្តើមប្រើប្រាស់ផលិតផល មុនដល់អាយុដែលណែនាំឱ្យប្រើប្រាស់បាន ហើយផលិតផលនេះអាចប្រើបានតែនៅពេលណាដែលមានការណែនាំពីបុគ្គលិកសុខាភិបាល ។

ច- ឃ្លាពន្យល់ថា ការបញ្ចុកដោយប្រើពែងមានអនាម័យច្រើនជាងការបំបៅដោយដប ។

ឆ- មិនត្រូវប្រើពាក្យបង្កប់ន័យថា ផលិតផលនេះប្រើសម្រាប់ជំនួសទឹកដោះម្តាយ ឬពាក្យប្រហាក់ប្រហែល។

ជ- មិនត្រូវមានរូបថត រូបគំនូរ ឬក្រាហ្វិកតំណាង ក្រៅពីការបង្ហាញនូវវិធីរៀបចំផលិតផលដែលបានកំណត់នោះឡើយ ។

ឈ- ឃ្លាចង្អុលបញ្ជាក់ពីតម្លៃថវិកាសរុបសម្រាប់ចិញ្ចឹមទារកក្នុងរយៈពេល ៦ ខែ ។

**មាត្រា ១០.-**

ផលិតផលប្រហាក់ប្រហែលផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ មិនមាននូវសារជាតិចិញ្ចឹម

គ្រប់គ្រាន់ តាមតម្រូវការរបស់ទារក និងកុមារ ត្រូវតែមានបម្រាមថា ផលិតផលនេះមិនមែនសម្រាប់ចិញ្ចឹមទារក និងកុមារឡើយ ។

**មាត្រា ១១.-**

នៅលើស្លាកដបបំបៅ ឬកញ្ចប់ ឬសម្បកផលិតផលដបបំបៅ ឬក្បាលដោះជ័រ ត្រូវសរសេរ ÷

១- ពាក្យថា គ្មានអ្វីប្រសើរជាងទឹកដោះម្តាយ ក្នុងការចិញ្ចឹមទារក និងកុមារតូចៗឡើយ ។

២- ការបញ្ចុកទារកដោយប្រើពែង មានសុវត្ថិភាពជាងការបំបៅដោយដប ។

៣- ការណែនាំអំពីរបៀបលាងសម្អាត និងស្ងោររំងាប់មេរោគដបបំបៅ និងក្បាលដោះជ័រឱ្យបានត្រឹមត្រូវ ។

៤- បម្រាមអំពីគ្រោះថ្នាក់ដល់សុខភាពដែលអាចបណ្តាលមកពីការប្រើប្រាស់ដបបំបៅ ជាពិសេសប្រសិនបើពុំបានស្ងោររំងាប់មេរោគអោយបានត្រឹមត្រូវ ។

៥- បម្រាមអំពីឥទ្ធិពលជាអវិជ្ជមាននៃការបំបៅដោយដប និងតម្រូវការអោយមានការអនុវត្តតាមការណែនាំអំពីការរៀបចំដោយប្រុងប្រយ័ត្ន ដើម្បីធានាថាទារកមិនធ្លាក់ខ្លួនឈឺ ។

៦- ឈ្មោះ និងអាស័យដ្ឋានរបស់ផលិតករ ឬអ្នកចែកចាយផលិតផល ឬភ្នាក់ងារតាមមូលដ្ឋាន ។

៧- ការប្រើប្រាស់ក្បាលដោះជ័រនិងដបបំបៅ អាចធ្វើអោយរំខានដល់ការបំបៅកូនដោយទឹកដោះម្តាយ ។

**មាត្រា ១២.-**

នៅលើកំប៉ុង ឬស្លាកដែលបិទនៅលើកំប៉ុងទឹកដោះគោផ្អែមខាប់ ឬទឹកដោះគោគ្មានក្រែម ឬផលិតផលប្រហាក់ប្រហែល ត្រូវមានបម្រាមអោយបានច្បាស់ និងលេចធ្លោថា មិនត្រូវប្រើប្រាស់ផលិតផលនេះសម្រាប់ចិញ្ចឹមទារក និងកុមារតូចៗទេ ។

## ជំពូកទី ៥
## ការហាមឃាត់

**មាត្រា ១៣.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ផលិតករ ឬអ្នកចែកចាយ មិនត្រូវធ្វើការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលសម្រាប់ចិញ្ចឹម ទារក និងកុមារតូចៗ ដូចមានចែងក្នុងអនុក្រឹត្យនេះ ដោយខ្លួនឯង ឬដោយការចាត់តាំងតំណាងរបស់ខ្លួននៅតាមកន្លែងដាក់លក់ក្នុងមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ឬទីកន្លែងផ្សេងទៀតឡើយ ។ ខាងក្រោមនេះ គឺជាផ្នែកមួយ នៃសកម្មភាពផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ដែលត្រូវហាមឃាត់ ÷

ក- ការឃោសនាពាណិជ្ជកម្ម ។

ខ- ការប្រើប្រាស់មធ្យោបាយដែលជាល្បិចកលក្នុងគោលបំណងលក់ផលិតផល រួមមានការដាក់តាំងបង្ហាញពិសេស ប័ណ្ណបញ្ចុះតម្លៃភាគរយ ការលក់ថែម ការលក់ដោយផ្តល់កំរៃជើងសារ ការលក់បញ្ចុះតម្លៃ ការលក់ជឿ ការផ្តល់រង្វាន់លើកទឹកចិត្តដល់ការទិញ ការលក់តម្លៃពិសេស ឬការផ្តល់ជាអំណោយ។ ប៉ុន្តែកថាខណ្ឌ ខ នៃមាត្រានេះ មិនកម្រិតល័ក្ខខ័ណ្ឌទៅលើការកំណត់គោលនយោបាយតម្លៃ និងការអនុវត្តដែលមានគោលបំណងផ្តល់នូវផលិតផលដែលបានកំណត់នេះ ក្នុងតម្លៃកាន់តែទាបសម្រាប់រយៈពេលយូរនោះឡើយ។

គ- ការផ្តល់គំរូសាកផលិតផលដែលបានកំណត់មួយ ឬច្រើនដល់ជនណាម្នាក់ ។

ឃ- ការបរិច្ចាគ ឬចែកចាយសម្ភារៈឯកសារព័ត៌មាន ឬសម្ភារៈឯកសារអប់រំស្តីពីការចិញ្ចឹមទារក និងកុមារ ឬការអនុវត្តមុខងារអប់រំ ទាក់ទងទៅនឹងការចិញ្ចឹមទារក និងកុមារតូចៗអាចធ្វើទៅបានលុះត្រាតែផលិតករ និងអ្នកចែកចាយ អាចផ្តល់ព័ត៌មានស្តីពីផលិតផលដែលបានកំណត់ដល់បុគ្គលិកសុខាភិបាលដែលព័ត៌មាននោះ កម្រិតល័ក្ខខ័ណ្ឌទៅលើបញ្ហាវិទ្យាសាស្ត្រ និងបញ្ហាជាក់ស្តែងទាក់ទងនឹងទិដ្ឋភាពបច្ចេកទេស និងវិធីសាស្ត្រប្រើប្រាស់ផលិតផលដែលបានកំណត់ ហើយស្របទៅតាមបញ្ញត្តិនៃមាត្រា ៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៥.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ផលិតករ ឬអ្នកចែកចាយ ទោះជាដោយខ្លួនឯងផ្ទាល់ ឬតាមរយៈជនណាម្នាក់ដែលជាតំណាងរបស់ខ្លួនក្តី មិនត្រូវ ÷

ក- បរិច្ចាគ ឬចែកចាយដល់បុគ្គលិកសុខាភិបាល ឬមន្ទីរពេទ្យ ឬមណ្ឌលសុខភាព នូវសម្ភារៈ ឬគំរូសាកផលិតផលដែលបានកំណត់នោះឡើយ ។

ខ- បរិច្ចាគ ឬធ្វើការចែកចាយ ដល់មន្ទីរពេទ្យឬមណ្ឌលសុខភាព នូវគ្រឿងបរិក្ខារ សម្ភារៈ ឬឯកសារ ឬសេវាដែលបង្ហាញ ឬមានដាក់ឈ្មោះ ផ្លាកសញ្ញា សញ្ញាពាណិជ្ជកម្ម ឬសេចក្តីពិពណ៌នា របស់ផលិតករ អ្នកចែកចាយ ឬនៃផលិតផលដែលបានកំណត់ ដែលមានបង្ហាញ ឬផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកំណត់នេះឡើយ ។

គ- បរិច្ចាគ ឬចែកចាយ ដល់មន្ទីរពេទ្យ ឬមណ្ឌលសុខភាព នូវសម្ភារៈ ដូចជា ប៊ិច ប្រតិទិន ផ្ទាំងរូបភាព សៀវភៅសរសេរ តារាងតាមដានការលូតលាស់ និងប្រដាប់ក្មេងលេង ដែលមានបង្ហាញ ឬផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកំណត់នេះឡើយ ។

ឃ- ផ្តល់ជាអំណោយ វិភាគទាន ឬផលប្រយោជន៍អ្វីមួយ ដល់បុគ្គលិកសុខាភិបាល ឬ សមាជិកបុគ្គលិកសុខាភិបាល ដែលធ្វើការងារក្នុងផ្នែកសុខភាពមាតា និងទារកឡើយ ។

ង- ឧបត្ថម្ភដល់ពិធីផ្សេងៗ កម្មវិធីប្រលងកំសាន្ត បណ្តាញទូរស័ព្ទសម្រាប់ការផ្តល់ប្រឹក្សា ឬ យុទ្ធនាការដែល

មានផ្តោតទៅលើស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន ឪពុក-ម្តាយរបស់ទារក និងកុមារ ឬសមាជិកគ្រួសារ និងមិនត្រូវឧបត្ថម្ភដល់ពិធីផ្សេងៗ កម្មវិធីល្បែងកំសាន្ត បណ្តាញទូរស័ព្ទសម្រាប់ផ្តល់ប្រឹក្សា ឬយុទ្ធនាការ ដែលពាក់ព័ន្ធទៅនឹងសុខភាពបន្តពូជ ការមានផ្ទៃពោះ ការសម្រាលកូន ការចិញ្ចឹមទារក និងកុមារ ឬប្រធានបទណាមួយដែលពាក់ព័ន្ធឡើយ ។

ច- ផ្តល់អាហារូបករណ៍ដោយផ្ទាល់ ឬដោយប្រយោល ការឧបត្ថម្ភដល់ការស្រាវជ្រាវ ឬផ្តល់ថវិកាសម្រាប់ការប្រជុំ សិក្ខាសាលា វគ្គអប់រំបន្ត ឬសន្និសីទ ដោយគ្មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសុខាភិបាលឡើយ ។

ឆ- ផ្តល់ ឬឱ្យប្រាក់ខែដល់អ្នកតំណាងវិជ្ជាជីវៈផ្តល់សេវា អ្នកមានជំនាញថែទាំទារក ឬបុគ្គលិកដែលមានជំនាញប្រហាក់ប្រហែល នៅតាមមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ។

ជ- ដាក់បញ្ចូលទំហំនៃការលក់ដូរផលិតផលដែលបានកំណត់ នៅពេលទូទាត់ប្រាក់បំណាច់ដល់និយោជិក និងមិនត្រូវកំណត់ចំនួនកូតាសម្រាប់ការលក់ផលិតផលដែលបានកំណត់នោះឡើយ ។

**មាត្រា ១៥.-**

ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល គ្រប់គ្រឹះស្ថានសុខភាព ទាំងសាធារណៈ និងទាំងឯកជនរួមទាំងបុគ្គលិកសុខាភិបាល ដែលបម្រើការងារផ្នែកសុខភាពមាតា និងទារកផង មិនត្រូវ ៖

ក- ទទួលយកអំណោយ វិភាគទាន ឬផលប្រយោជន៍ផ្សេងៗ ថវិកា ឬវត្ថុមានតម្លៃអ្វីមួយពីផលិតករ ឬអ្នកចែកចាយ ឬពីបុគ្គលណាម្នាក់ដែលជាតំណាងផលិតករឡើយ ។

ខ- ធ្វើការបង្ហាញអំពីវិធីប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្តឡើយ លើកលែងតែស្ត្រីជាមាតា ឬសមាជិកគ្រួសារ ដែលស្ថិតក្នុងករណីពិសេសចាំបាច់បំផុត ហើយ ក្នុងករណីបែបនេះ ត្រូវធ្វើការពន្យល់ឱ្យបានច្បាស់អំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រើប្រាស់ទឹកដោះគោម្សៅផ្សំតាមរូបមន្ត រួមទាំងព័ត៌មានផ្សេងទៀត ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះឡើយ ។

គ- ទទួលយក ឬផ្តល់គំរូសាក ឬផ្គត់ផ្គង់ផលិតផលដែលបានកំណត់ ដល់បុគ្គលណាម្នាក់ឡើយ ។

ឃ- ធ្វើការវាយតម្លៃវិជ្ជាជីវៈ ចុះសិក្សាស្រាវជ្រាវ ឬអនុវត្តសកម្មភាពផ្សេងទៀត នៅតាមមន្ទីរពេទ្យឬមណ្ឌលសុខភាព ទាក់ទងនឹងផលិតផលដូចដែលបានកំណត់ខាងលើ ។

**មាត្រា ១៦.-**

ផលិតករ ឬអ្នកចែកចាយផលិតផល សម្រាប់ចិញ្ចឹមទារក និងកុមារ អាចបរិច្ចាគ គ្រឿងបរិក្ខារ និងសម្ភារៈ ដល់គ្រប់គ្រឹះស្ថានសុខភាព ទាំងសាធារណៈ និងទាំងឯកជន តាមការស្នើសុំជាលាយល័ក្ខណ៍អក្សររបស់សាមីអង្គភាព ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

# ជំពូកទី ៦
# សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

**មាត្រា ១៧.–**

ក្រសួងសុខាភិបាលជាសមត្ថកិច្ចទទួលខុសត្រូវ សហការ សម្របសម្រួលការអនុវត្តភារកិច្ចចិញ្ចឹមទារក និងកុមារតូចៗអោយមានប្រសិទ្ធភាពជាមួយក្រសួងពាក់ព័ន្ធតាមសមត្ថកិច្ចរៀងៗខ្លួនដូចខាងក្រោម ÷

ក- ផ្តល់យោបល់ដល់គណៈកម្មាធិការជាតិអាហារូបត្ថម្ភ អំពីគោលនយោបាយជាតិសម្រាប់ការលើកកម្ពស់ និងទិសដៅយុទ្ធសាស្ត្រជាតិគាំពារការបំបៅកូនដោយទឹកដោះម្តាយ ។

ខ- ផ្តល់យោបល់ជូនអំពីអាហារូបត្ថម្ភស្តីអំពី ÷

- ការរៀបចំយុទ្ធសាស្ត្រជាតិ សម្រាប់រៀបចំកម្មវិធីអប់រំសាធារណៈ និងសម្ភារៈសម្រាប់អប់រំ ។
- លើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយ
- សម្ភារៈឬឯកសារអប់រំ និងព័ត៌មានផ្សព្វផ្សាយ ទាក់ទងនឹងប្រធានបទស្តីពីការចិញ្ចឹមទារក និងកុមារតូចៗ
- ការបន្តអប់រំដល់បុគ្គលិកសុខាភិបាល ពីរបៀបគ្រប់គ្រងទឹកដោះម្តាយ
- កម្មវិធីសិក្សាស្តីពីរបៀបគ្រប់គ្រងទឹកដោះម្តាយសម្រាប់និស្សិតពេទ្យ ។

គ- ធ្វើការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធក្នុងវិស័យសុខុមាលភាពកុមារ និងការអភិវឌ្ឍអាហារូបត្ថម្ភសម្រាប់កុមារ ឬការការពារទារក និងកុមារតូចៗ ។

ឃ- ធានាធ្វើយ៉ាងណាអោយមានការផ្សព្វផ្សាយអោយបានទូលំទូលាយនូវច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ និងការប្រកាសផ្សាយនៅទូទាំងប្រទេស ។

ង- ពិនិត្យលើរបាយការណ៍ ទាក់ទងនឹងការបំពានច្បាប់ ឬបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍អនុក្រឹត្យនេះ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

ច- ធ្វើការផ្សព្វផ្សាយនូវសេចក្តីណែនាំដល់ក្រុមមន្ត្រីត្រួតពិនិត្យដើម្បីលើកឡើងនូវករណីទាំងឡាយណា ដែលបានប្រព្រឹត្តខុសពីអនុក្រឹត្យនេះ ឬប្រព្រឹត្តបំពាននឹងច្បាប់ជាធរមាន ។

ឆ- ពិចារណាពីភាពចាំបាច់ណាមួយសម្រាប់ក្រសួងសុខាភិបាល និងក្រសួងពាណិជ្ជកម្ម ធ្វើការអនុវត្តយ៉ាងពេញលេញនូវបទប្បញ្ញត្តិនៃច្បាប់នានា ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ជ- ស្នើ និងបញ្ជូននូវវត្ថុធាតុជាអាហារូបត្ថម្ភ ទៅមន្ទីរពិសោធន៍ ឬធ្វើតេស្តតាមការចាំបាច់ ។

ឈ- ស្វែងរកថវិកា និងជំនួយពីប្រភពអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ផ្តល់ជំនួយនានា ។

ញ- បំពេញតួនាទី និងសមត្ថកិច្ចចាំបាច់នានា ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព ផលិតផល ទំនិញ និងសេវា ។

ដ- មានសិទ្ធិចេញសេចក្តីសម្រេចចាំបាច់ ទាក់ទងនឹងការអនុវត្តនីអនុក្រឹត្យនេះ និងច្បាប់ពាក់ព័ន្ធ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ឋ- កំណត់វិធានការជាតិ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យនេះ និងធ្វើការត្រួតពិនិត្យលើផែនការសកម្មភាពចាំបាច់ទាំងឡាយ ។

ឌ- បំពេញភារកិច្ចពាក់ព័ន្ធដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ១៨.-**

ការអនុវត្តទោសប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផលសំរាប់ចិញ្ចឹម ទារក និងកុមារ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា ឬតាមច្បាប់ផ្សេងៗទៀតជាធរមាន ។

**មាត្រា ១៩.-**

អាជ្ញាធរមានសមត្ថកិច្ចក្នុងការបំពេញភារកិច្ចរបស់ខ្លួន ត្រូវគោរពតាមនីតិវិធី ដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា និងតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ២០.-**

ក្នុងរយៈពេលប្រាំមួយ (៦) ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ផលិតករ ឬអ្នកចែកចាយផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ត្រូវបំពេញបែបបទ ដែលកំណត់ដោយក្រសួងសុខាភិបាលឱ្យបានត្រឹមត្រូវតាមបញ្ញត្តិជាធរមាន ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២២
- ឯកសារ-កាលប្បវត្តិ